# ក្រសួងពាណិជ្ជកម្ម

## នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

### គម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP)

**បទបង្ហាញស្តីពី: របកគំហើញ និង កិច្ចការទូទៅ នៃផ្នែកហិរញ្ញវត្ថុ**

**ភ្នំពេញ, ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២**

# ចំនុចសំខាន់ៗ នៃបទបង្ហាញ

១)- ការរៀបចំផែនការវគ្គបណ្តុះបណ្តាលសម្រាប់គម្រោងទាំងប្រាំ ដែលបានអនុម័តក្រោយគេក្នុងឆ្នាំ២០១១

២)- គម្រោងជាអាទិភាពចំនួនប្រាំ ដែលត្រូវលើកស្នើមកនាយកគ្រប់គ្រងគម្រោងសម្រាប់ឆ្នាំ២០១២

៣)- របាយការណ៍របកគំហើញផ្សេងៗ ដែលទាក់ទងនឹងការស្នើសុំបុរេប្រទាន និងការទូទាត់ជម្រះបញ្ជី

# គម្រោងដែលត្រូវរៀបចំផែនការវគ្គបណ្តុះបណ្តាលប្រចាំឆ្នាំ ២០១២

១). **MoC ICT Master Plan**

- សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលសរុបចំនួន៨ **សរុបទឹកប្រាក់ចំនួន ១២៦,០០០ ដុល្លារអាមេរិក**

២). **GDCE Capacity Enhancement Programme**

- សិក្ខា សាលា វគ្គបណ្តុះបណ្តាល និងដំណើរទស្សនៈកិច្ចសិក្សានៅក្រៅប្រទេសសរុបចំនួន១០ **សរុបទឹកប្រាក់ចំនួន២០៣,៧៣០ ដុល្លារអាមេរិក**

៣). **Implementing Agencies Capacity Enhancement Program (IACEP)**

- សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលសរុបចំនួន៤ **សរុបទឹកប្រាក់ចំនួន ៣៧,៥០០ ដុល្លារអាមេរិក**

៤). **The development of national standards for rice and strengthening the capacity of conformity assessment body-Phase I (MIME)**

- សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលសរុបចំនួន២ និងប្រមូលទិន្នន័យសរុបចំនួន២ **សរុបទឹកប្រាក់ចំនួន៤៩,០៥៨.៥០ ដុល្លារអាមេរិក**

៥). **Better Quality and Safety of Fish and Fishery Products for Improving Fish Trade Development in Cambodia**

- សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលសរុបចំនួន២០ **សរុបទឹកប្រាក់ចំនួន៧៧,៥៥៩.០០ ដុល្លារអាមេរិក**

# សំណើគម្រោងជាអាទិភាពប្រចាំឆ្នាំ២០១២

| ឈ្មោះគម្រោង | ថវិកាវិភាជន៍ |
|---|---|
| ១). Automating IP Administration System | USD296,000.00 |
| ២). Capacity Building of Internal Audit Dep’t | USD356,000.00 |
| ៣). SEZ Automation | USD31,400.00 |
| ៤). Support to GPSF | USD300,000.00 |
| ៥). Electronic Platform to Support Exporting Agricultural Products | USD300,000.00 |

# របាយការណ៍របកគំហើញរបស់ផ្នែកហិរញ្ញវត្ថុ

- ភ្នាក់ងារអនុវត្តមួយចំនួន មានការជម្រះបញ្ជីសាច់ប្រាក់បុរេប្រទានសម្រាប់រៀបចំសិក្ខា សាលា វគ្គបណ្ដុះបណ្ដាល និងដំណើរទស្សនៈកិច្ចសិក្សាក្នុង និងក្រៅប្រទេស មានការយឺតយ៉ាវលើសចំនួន១០ថ្ងៃ ក្រោយសកម្មភាពបានបញ្ចប់ ។

  Some Implementing Agencies liquidated the advance for Training, Workshop, and Inbound & Outbound Study Tour is more than 10 working days after the events is completed.

- ការដាក់សំណើរសុំសាច់ប្រាក់បុរេប្រទានសម្រាប់អនុវត្តសកម្មភាពនានា មកផ្នែកហិរញ្ញវត្ថុគម្រោង មានពេលតិចជាង៥ថ្ងៃ ឬក្នុងរយៈពេលសកម្មភាពកំពុងអនុវត្ត ។

  Submitting the request for advance to implement the activities to Finance Unit of TDSP is less than 5 working days or in the same time of activities is holding.

- ចំណាយទិញសម្ភារៈការិយាល័យ និងការថតចម្លងឯកសារសម្រាប់អ្នកចូលរួម ត្រូវបានទិញជាកញ្ចប់ មិនបានលំអិតតម្លៃ និងឯកត្តានៃទំនិញនីមួយៗ ឬក៏ទំព័រ ។

  The Payment for office supplies and stationeries and copy and binding document for participants were bought in the package. It was not detailed cost itemize and cost per unit or per page.

- វិក្កយបត្រទិញទំនិញមួយចំនួន មិនបានបរិយាយមុខទំនិញដែលបានទិញ កាលបរិច្ឆេទ ហត្ថលេខា និងឈ្មោះអ្នកទិញ និងអ្នកលក់ និងបានលក់ទៅឲ្យអ្នកណា ។

  Some invoices did not descript the items, date, signature, buyer, seller, and who bought (sell to who)

- ភ្នាក់ងារអនុវត្តមួយចំនួន បានជួលឧបករណ៍ប្រើប្រាស់សម្រាប់ជំនួយក្នុងអង្គសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល នៅពេលដែលឧបករណ៍ដូចគ្នានោះត្រូវបានផ្តល់ឲ្យដោយគម្រោងរួចហើយ ។
- Some Implementing Agencies hired some equipment to support their training and workshop as the same those equipments were already distributed by the project.
- លិខិតស្នើសុំសម្រង់តម្លៃ និងលិខិតបញ្ជាទិញទំនិញ និងសេវាកម្មនានា មិនត្រូវបានប្រើប្រាស់ជាទូទៅសម្រាប់ធានារាល់ការទូទាត់ចំណាយ ។
- Request for Quotation and Purchase Order to buy goods and services are not universally used to support the payments.

- វិក្កយបត្រសម្រាប់ការទូទាត់ចំណាយទិញទំនិញ និងសេវាកម្មរបស់អ្នកផ្គត់ផ្គង់ជាច្បាប់ចម្លងដែលទុកសម្រាប់ប្រើប្រាស់កិច្ចការផ្ទៃក្នុងរបស់គេ ហើយក៏មានការប្រើប្រាស់របាយការណ៍ពិនិត្យដើម្បីជួសជុល ជំនួសវិក្កយបត្រផងដែរ ។

  Some of supplier's invoice for payment for goods and services are copy documents which for internal use only and have found that the services report sheet was used in absent the invoice.

- លិខិតបញ្ជាបេសកកម្ម និងទិដ្ឋាការធ្វើដំណើររបស់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលមិនបានបំពេញត្រឹមត្រូវ ។
- National and sub national level's mission letter and visa which attended the training and workshop are not completely fill up.

- សម្រាប់អង្គសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗរបស់គម្រោង ផ្នែកហិរញ្ញវត្ថុបានរកឃើញថា ភ្នាក់ងារអនុវត្តបានអនុញ្ញាតឲ្យប្រពន្ធផ្សព្វផ្សាយចូលរួម ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មាន សកម្មភាពរបស់គម្រោង ។

  For training and workshop of the project. Finance Unit found that some implementing agency allow reporter/journalist attend to disseminate the project’s activities.

- មានការប្រើប្រាស់កញ្ចប់បេឡាសាច់ប្រាក់ដើម្បីទិញឧបករណ៍ទប់ចរន្តអគ្គីសនីចំនួនប្រាំគ្រឿង និងឧបករណ៍ភ្ជាប់អ៊ីនធឺណែត ដោយមិនមានការជូនជាដំណឹងនិងការស្នើសុំជាមុនពីនាយកគម្រោង នៅពេលដែលឧបករណ៍ដូចគ្នានោះត្រូវបានផ្តល់ឲ្យ ដោយគម្រោងរួចហើយ ។

- We found that there are using the petty cash to buy UPS and internet connection materials without prior information to the national project director as the same of some of all these equipment were already provided by the project.

- វិក្កយបត្រទូទាត់របស់អ្នកផ្គត់ផ្គង់ ត្រូវបានភ្នាក់ងារអនុវត្តមួយចំនួនប្រើប្រាស់លេខរៀងវិក្កយបត្រទាំងអស់នោះតាមលំដាប់លេខរៀង ទោះបីជាកាលបរិច្ឆេទទិញទំនិញមានការខុសគ្នាក៏ដោយ ។
- Some implementing agencies used supplier’s invoice in the series number although difference date of buying.
- មានការចំណាយទិញសម្ភារ:និងសេវាកម្ម ដែលមានតម្លៃច្រើនជាង **USD200.00** (ពីររយដុល្លារអាមេរិក) ចេញពីកញ្ចប់បេឡាសាច់ប្រាក់របស់ភ្នាក់ងារអនុវត្ត ។

  There are some payments to buy materials and services which cost per transaction more than USD200.00 (Two Hundred US Dollars) from the IA petty cash book.

- ការចំណាយទិញទឹក តែ និងកាហ្វេ សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ត្រូវបានឃើញកើតមានចំពោះភ្នាក់ងារអនុវត្តមួយចំនួន ។
- We found that some implementing agencies spent petty cash to buy pure water, tea, and coffee for daily use.
- មន្ត្រីបង្គោល និងភ្នាក់ងារដែលមានភារៈកិច្ចធ្វើការទំនាក់ទំនងជាមួយផ្នែកហិរញ្ញវត្ថុ មិនមែនជាមន្ត្រីតែមួយរូប ។
- Focal person and staffs which nominated to facilitate with finance unit is not only one person.

- ការមិនបានបង្ហាញឲ្យបានច្បាស់លាស់នូវឈ្មោះ និងលេខអនុស្សារណៈនៃការយោគយល់ នៅលើឯកសាររដ្ឋបាល និងឯកសារចំណាយផ្សេងៗ ជាហេតុបណ្តាលឲ្យមានការលំបាកក្នុងការកត់ត្រាចំណូល និងចំណាយរបស់គម្រោង ។

  There is no mention clearly about the title of project and number of MoU on administration documents and expenditure documents is cause difficulty to capture the project’s receipt and payments.

- ការបរិយាយនូវគោលបំណងនៃការចំណាយ និងការបរិយាយឯកសារភ្ជាប់គាំទ្រការចំណាយមិនបានឆ្លុះបញ្ចាំងនូវគោលបំណងនៃការចំណាយនោះឡើយ ។ ជាក់ស្តែង ចំណាយសម្រាប់បៀវត្ស៍ទីប្រឹក្សា តែបរិយាយបង្កើតកញ្ចប់បេឡាសាច់ប្រាក់ និងឯកសារគាំទ្រការចំណាយសេវាកម្មរបស់ក្រុមហ៊ុន តែការភ្ជាប់ឯកសារបង្កើតបេឡាសាច់ប្រាក់ ។

  The purpose description of expenditure and explanation on supporting documents do not reflect to the purpose of the actual expenditure. Actually, the payment for consultant’s remuneration but mentioned that initial the petty cash book and the documents to support the expenditure for the services of company but the attached documents are mentioned petty cash establishment.

- ភ្នាក់ងារអនុវត្តបានអនុម័តទូទាត់ចំណាយជូនទីប្រឹក្សា មិនបានពិនិត្យមើលសុពលភាពនៃការចាប់ផ្តើមការងារ និងសកម្មភាពការងាររបស់ទីប្រឹក្សាធៀបនឹងកិច្ចសន្យាដែលបានព្រមព្រៀងជាមួយគម្រោង ។

  The payment for consultant remuneration are approved without check and review the consultant’s commencement date and monthly performance report against the term of reference and contract.

- ការចំណាយទូទាត់ប្រេងឥន្ធនៈសម្រាប់ទោចក្រយានយន្ត និងយានយន្តផ្ទាល់ខ្លួនគ្រប់ប្រភេទមិនត្រូវបានអនុញ្ញាប្រើប្រាស់ថវិការបស់គម្រោងឡើយ ។

  The payment of fuel consumption for individual motorbike and car are not allowed to spend the money from project.

- ភ្នាក់ងារអនុវត្តបានប្រើប្រាស់សេវាកម្មរបស់អ្នកផ្គត់ផ្គង់ច្រើនជាងមួយ នៅពេលដែលគណៈកម្មការ IOC Committee (Incremental Operating Cost Committee) បានយល់ព្រមផ្ដល់កិច្ចសន្យាដល់អ្នកឈ្នះទី១ ។

  Some IAs used two service providers in the same time when IOC committee award the contract to the first rank in bidding evaluation report.

- ភ្នាក់ងារអនុវត្តមួយចំនួន បានចំណាយទិញគ្រឿងសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់គាំទ្រសកម្មភាពគម្រោង មិនបានកត់ត្រាការទិញចូល និងការស្នើសុំប្រើប្រាស់ ។

  Some IAs spent the money to buy office supplies and stationeries to support project’s activities did not record in stock in and out.

- គម្រោងស្នើសុំឲ្យភ្នាក់ងារអនុវត្តទាំងអស់ បង្កើតត្រាជ្រុងមួយដូចមានគម្រូស្រាប់ ដើម្បីបោះលើឯកសារចំណាយទាំងឡាយ ជាពិសេសវិក្កយបត្រទូទាត់របស់អ្នកផ្គត់ផ្គង់ ដើម្បីចៀសវាងការប្រើប្រាស់ជាន់គ្នា ។

**Royal School of Administration**

Paid by: MoU No. TDSP 2010-018

Date: ............../............../..............

# សំណួរ និង ចម្លើយ

# សូមអរគុណ

Thank you